# របាយការណ៍រួមជូនក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ សម្រាប់ការត្រួតពិនិត្យមើលជាសកលតាមកាលកំណត់លើកទី ៣ លើព្រះរាជាណាចក្រកម្ពុជា

## និន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញទំនោរយេនឌ័រ និងលក្ខណៈភេទ (SOGIE) និង សិទ្ធិសុខភាពបន្តពូជ និងសិទ្ធិសុខភាពផ្លូវភេទ (SRHR) នៅកម្ពុជា

*ថ្ងៃទី១២ ខែ កក្កដា ឆ្នាំ២០១៨*

របាយការណ៍រួមរបស់មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") សហគមន៍ឥន្ទធនូកម្ពុជា ("រ៉ក់") អង្គការគោលដៅយុត្តិធម៌ ("DJ") មីក្រូឥន្ទធនូអន្តរជាតិ ("MRI") អង្គការថែទាំសុខភាពគ្រួសារកម្ពុជា ("រ៉ាក់") សមាគមអន្តរជាតិនៃស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ អ្នកប្តូរយេនឌ័រ និងអន្តរភេទនៅអាស៊ី ("ILGA-Asia"), ក្រុមការងារអាស៊ានស្តីពីនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញទំនោរនៃយេនឌ័រ ("ASC") សមាគមអប់រំផ្លូវភេទស៊ុយអែត ("RFSU") អាក់សិនអេតប្រចាំកម្ពុជា ("AAC"), ជំនួយរបស់វិហារដាណើម៉ាកកម្ពុជា ("DCA") និង សមាគមអនាគតយុវជនកម្ពុជា-អាស៊ាន ("CamASEAN")


មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR)
អ៊ីម៉ែល៖ info@cchrcambodia.org
ទូរស័ព្ទ៖ (+855) 23 726 901
Web: https://cchrcambodia.org

សហគមន៍ឥន្ទធនូកម្ពុជា (RoCK)
អ៊ីម៉ែល៖ contact@rockcambodia.org
ទូរស័ព្ទ៖ +855 12 481 561
Web: http://www.rockcambodia.org

គោលដៅយុត្តិធម៌ (DJ)
អ៊ីម៉ែល៖ info@destinationjustice.org
ទូរស័ព្ទ៖ +855 23 987 263
Web: http://destinationjustice.org

## I. សេចក្តីផ្តើម

1. របាយការណ៍រួមសម្រាប់ការត្រួតពិនិត្យមើលជាសកលតាមកាលកំណត់លើកទី ៣ ("UPR") លើព្រះរាជាណាចក្រកម្ពុជា ("កម្ពុជា") ត្រូវបានរៀបចំឡើងដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("CCHR") ១,សហគមន៍ឥន្ទធនូកម្ពុជា ("RoCK") ២, អង្គការគោលដៅយុត្តិធម៌ ("DJ")៣, មីក្រូឥន្ទធនូអន្តរជាតិ ៤, និងអង្គការថែទាំសុខភាពគ្រួសារកម្ពុជា ("RHAC") ៥, សមាគមអន្តរជាតិនៃស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ អ្នកប្តូរយេនឌ័រ និងអន្តរភេទ (ILGA) ៦, សមាគមអន្តរជាតិនៃស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ អ្នកប្តូរយេនឌ័រ និងអន្តរភេទ ប្រចាំនៅអាស៊ី (ILGA-Asia) ៧, ក្រុមការងារអាស៊ានស្តីពីនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញយេនឌ័រ ("ASC") ៨, សមាគមអប់រំផ្លូវភេទស៊ុយអែត ("RFSU")៩, អាក់សិនអេតកម្ពុជា ១០, ជំនួយរបស់វិហារដាណើម៉ាក កម្ពុជា ("DCA")១១, និងសមាគមអនាគតយុវជនកម្ពុជា-អាស៊ាន ("CamASEAN")១២, របាយការណ៍នេះ ផ្តោតសំខាន់ទៅលើការគោរពនិងអនុវត្តនូវកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់កម្ពុជា ពាក់ព័ន្ធនឹងនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញទំនោរនៃយេនឌ័រ និងលក្ខណៈភេទ (" SOGIESC") និងសិទ្ធិសុខភាពបន្តពូជ និងសិទ្ធិសុខភាពផ្លូវភេទ ("SRHR")។

2. ក្នុងអំឡុងពេល យូ.ភី.អ លើកទីពីររបស់ប្រទេសកម្ពុជា នាឆ្នាំ២០១៤ ពុំមានការផ្តល់អនុសាសន៍ណាមួយដល់រាជរដ្ឋាភិបាលកម្ពុជា ("RGC") ដែលជាក់លាក់ស្តីពីសិទ្ធិរបស់ស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ អ្នកប្តូរយេនឌ័រ អន្តរភេទ និងអ្នកមិនកំណត់ខ្លួនឯងជាក់លាក់ ("អ្នកស្រលាញ់ភេទដូចគ្នា" "LGBTIQ") នៅឡើយ ប៉ុន្តែមានអនុសាសន៍បានលើកឡើងពីរចំណុចជាក់លាក់ស្តីអំពី សិទ្ធិសុខភាពបន្តពូជ និងសិទ្ធិសុខភាពផ្លូវភេទ។[13]

3. សហគមន៍ និងសកម្មជន អ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា រីករាយជាមួយនឹងការអាចបង្ហាញជាសាធារណៈច្រើនគួរសម ដូចជាព្រឹត្តិការណ៍ពាក់ព័ន្ធអ្នកស្រឡាញ់ភេទដូចគ្នា ជាច្រើនបានកើតឡើង និងដោយមានការគាំទ្រពីសមាជិក និងស្ថាប័នមួយចំនួននៃរាជរដ្ឋាភិបាលកម្ពុជា ("RGC")។ ការងារបច្ចុប្បន្នរបស់ក្រសួងអប់រំ យុវជន និងកីឡាក្នុងការកែសម្រួលឡើងវិញទៅលើកម្មវិធីសិក្សា "បំណិនជីវិត" ដើម្បីដាក់បញ្ចូលសិទ្ធិនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញលក្ខណៈភេទ គឺពិតជាគួរឱ្យកោតសរសើរជាពិសេស។ ប៉ុន្តែ ច្បាប់និងគោលនយោបាយ ព្រមទាំងទម្លាប់នៃការអនុវត្តន៍ដែលមានចរិតរើសអើងជាច្រើននៅតែមាននៅឡើយ ក្នុងនោះរាប់ទាំងការអនុវត្តន៍របស់ប៉ូលីសកម្ពុជាមួយចំនួនផងដែរ។ ខណៈដែលគេគួរកោតសរសើរចំពោះវឌ្ឍនភាពដែលសម្រេចបានពាក់ព័ន្ធនឹងបរិយាប័ន្ន អ្នកស្រឡាញ់ភេទដូចគ្នា នៅក្នុងប្រទេសកម្ពុជានៅតែទទួលរងនូវទម្រង់ផ្សេងៗនៃការរើសអើងផ្នែកច្បាប់ និងសង្គមជាបន្តនៅឡើយដូច្នេះវាទាមទារឱ្យរាជរដ្ឋាភិបាលកម្ពុជាចាត់វិធានការដើម្បីធានានូវការគោរព និងអនុវត្តតាមកាតព្វកិច្ចសិទ្ធិមនុស្សអន្តរជាតិរបស់ប្រទេសកម្ពុជាពាក់ព័ន្ធនឹងសិទ្ធិរបស់ អ្នកស្រឡាញ់ភេទដូចគ្នា។

## *វិធីសាស្ត្រ*

4. នៅមុន យូ.ភី.អ លើកទីបីរបស់កម្ពុជា ម.ស.ម.ក និង រ៉ក់ បានរៀបចំកិច្ចពិគ្រោះយោបល់ថ្នាក់ជាតិមួយ ដើម្បីរៀបចំរបាយការណ៍មួយផ្តោតសំខាន់ទៅលើសិទ្ធិ និន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញលក្ខណៈភេទ និង សិទ្ធិសុខភាពបន្តពូជ និងសិទ្ធិសុខភាពផ្លូវភេទ ។ ដៃគូនានាបានជួបជុំគ្នានៅក្នុងអំឡុងកិច្ចប្រជុំពិគ្រោះយោបល់ជាច្រើនជាមួយអង្គការសង្គមស៊ីវិល ("CSOs") និងសហគមន៍ដើម្បីកំណត់រកបញ្ហាអាទិភាពដែលពាក់ព័ន្ធនឹងសិទ្ធិរបស់អ្នកស្រឡាញ់ភេទដូចគ្នានៅក្នុងប្រទេសកម្ពុជា។[14] របាយការណ៍រួមនេះ ពិនិត្យទៅលើបញ្ហាសំខាន់ៗ ទៅលើការរើសអើងផ្នែកច្បាប់ទៅលើប្រជាជនអ្នកស្រឡាញ់ភេទដូចគ្នា ការរើសអើងផ្នែកសង្គមទៅលើប្រជាជនអ្នកស្រឡាញ់ភេទដូចគ្នា ឱកាសការងារ និងស្ថានភាពសេដ្ឋកិច្ចរបស់ប្រជាជនអ្នកស្រឡាញ់ភេទដូចគ្នា ស្ថានភាពរបស់មនុស្សអន្តរភេទ សិទ្ធិសុខភាពរបស់ប្រជាជនអ្នកស្រឡាញ់ភេទដូចគ្នា និងរួមបញ្ចូលទាំង និន្នាការភេទ អត្តសញ្ញាណយេនឌ័រនិងការបង្ហាញលក្ខណៈភេទនិងការអប់រំអំពីផ្លូវភេទគ្រប់ជ្រុងជ្រោយនៅតាមសាលារៀន។

## II. ការរើសអើងផ្នែកច្បាប់ទៅលើ អ្នកស្រឡាញ់ភេទដូចគ្នា

5. អ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា ប្រឈមមុខនឹងការរើសអើងជាច្រើនទម្រង់ មួយផ្នែកគឺដោយសារក្របខ័ណ្ឌច្បាប់បដិសេធនូវសមភាពជាមូលដ្ឋានចំពោះពួកគេ។ ការរើសអើងផ្នែកច្បាប់ ៤ ទម្រង់ ត្រូវបានបង្ហាញនៅក្នុងផ្នែកនេះ មានដូចជាកង្វះការការពារផ្នែកច្បាប់ប្រឆាំងនឹងការរើសអើង និងអំពើហិង្សាទៅលើប្រជាជន អ្នកស្រឡាញ់ភេទដូចគ្នា អវត្តមាននៃការទទួលស្គាល់ផ្លូវច្បាប់នៃអត្តសញ្ញាណយេនឌ័រដែលកំណត់ដោយខ្លួនឯង អវត្តមាននៃសមភាពអាពាហ៍ពិពាហ៍នៅក្នុងច្បាប់កម្ពុជា និងការបដិសេធសិទ្ធិសុំកូនពេញលេញចំពោះដៃគូឥន្ទធនូ (គូស្រករអ្នកស្រឡាញ់ភេទដូចគ្នា)។[15]

## *ការការពារប្រឆាំងនឹងការរើសអើងនិងអំពើហិង្សា*

6. ក្របខ័ណ្ឌច្បាប់កម្ពុជា ពុំមានចែងអំពីការការពារច្បាស់លាស់ពីការប្រឆាំងនឹងការរើសអើងដោយសារហេតុផល និន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញលក្ខណៈភេទឡើយ។ មាត្រា៣១ នៃរដ្ឋធម្មនុញ្ញធានាសិទ្ធិស្មើគ្នាចំពោះប្រជាជនកម្ពុជាគ្រប់រូបដោយមិនគិតពីលក្ខណៈបុគ្គលិក ហើយខណៈដែលប្រជាជនអ្នកស្រឡាញ់ភេទដូចគ្នាត្រូវបានការពារ នៅក្រោមប្រភេទ «ស្ថានភាពផ្សេងទៀត» ការរាប់បញ្ចូលច្បាស់លាស់នូវប្រភេទចំនួន ៩ ផ្សេងទៀត ទំនងជាធ្វើឱ្យហេតុផលនេះមិនសូវមានទម្ងន់។[16] ស្រដៀងគ្នានេះដែរ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ("Criminal Code") មិនបានដាក់បញ្ចូល និន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញលក្ខណៈភេទ ជាមូលដ្ឋានហាមឃាត់សម្រាប់ការរើសអើងនោះទេ។[17]

7. ក្រមព្រហ្មទណ្ឌពុំមានចែងអំពីទោសទណ្ឌច្បាស់លាស់ចំពោះជនទាំងឡាយ ដែលប្រព្រឹត្តអំពើស្អប់ខ្ពើមមកលើប្រជាជនអ្នកស្រឡាញ់ភេទដូចគ្នាឡើយ។ កង្វះនៃការការពារ ប្រឆាំងការរើសអើង រួមផ្សំនឹងអវត្តមាននៃទោសទណ្ឌដែលកំណត់ច្បាស់លាស់ចំពោះជនទាំងឡាយដែលប្រព្រឹត្តអំពើស្អប់ខ្ពើម គឺជាប្រការដ៏គួរឱ្យព្រួយបារម្ភ ជាពិសេស នៅក្នុងបរិបទកម្ពុជាដែលប្រជាជន អ្នកស្រឡាញ់ភេទដូចគ្នា ប្រឈមមុខនឹងការរើសអើង និងអំពើហិង្សាជាច្រើនទម្រង់នៅក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់ខ្លួន។[18] ឧទាហរណ៍ ៩២% នៃអ្នកប្តូរយេនឌ័រជាពីបុរសទៅស្ត្រី ដែល ម.ស.ម.ក បានស្ទង់មតិកាលពីឆ្នាំ២០១៦ បានរាយការណ៍ថា ធ្លាប់ទទួលរងនូវការបំពានដោយពាក្យសម្តីនៅតាមទីសាធារណៈដោយសារតែអត្តសញ្ញាណប្តូរយេនឌ័ររបស់ខ្លួន ខណៈដែល ៤៣% នៃពួកគេ បានរាយការណ៍ថា ធ្លាប់ទទួលរងអំពើហិង្សាលើរាងកាយ និង ៣១% ធ្លាប់ទទួលរងការរំលោភបំពានផ្លូវភេទ។[19] អត្រាខ្ពស់នៃអំពើហិង្សាទៅលើប្រជាជន អ្នកស្រឡាញ់ភេទដូចគ្នា ក៏ត្រូវបានកត់សម្គាល់ផងដែរ ដោយអ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិ ស្តីពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា កាលពីឆ្នាំ២០១៧។[20]

8. មាត្រា ២(១) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ក.អ.ស.ព.ន") ត្រូវបានបកស្រាយយ៉ាងច្បាស់លាស់ដោយគណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ដើម្បីហាមប្រាមការរើសអើងដោយផ្អែកលើមូលដ្ឋាននៃនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ។[21] ក្នុងនាមជាភាគីនៃ ("ក.អ.ស.ព.ន") កម្ពុជាមានកាតព្វកិច្ចវិជ្ជមានក្នុងការធានាសិទ្ធិ("ក.អ.ស.ព.ន")ក្នុងនោះរួមទាំងការចាត់វិធានការផ្នែកច្បាប់ដើម្បីការពារបុគ្គលទាំងឡាយពីការរំលោភបំពានសិទ្ធិ ("ក.អ.ស.ព.ន") ដែលតួអង្គរដ្ឋ និងឯកជនបានសន្យាគោរព និងអនុវត្ត។[22]

## ការទទួលស្គាល់យេនឌ័រតាមផ្លូវច្បាប់

9. ការទទួលស្គាល់យេនឌ័រតាមផ្លូវច្បាប់ តម្រូវឱ្យមានការរៀបចំ និងដាក់ឱ្យអនុវត្តនូវនីតិវិធីច្បាប់ និងរដ្ឋបាលដែលផ្តល់លទ្ធភាពដល់ការឆ្លុះបញ្ចាំងអំពីយេនឌ័រដែលកំណត់ដោយខ្លួនឯងរបស់ប្រជាជនដែលប្តូរយេនឌ័រនៅលើឯកសារអត្តសញ្ញាណផ្លូវការរបស់ពួកគេ ដូចជា សំបុត្របញ្ជាក់កំណើត អត្តសញ្ញាណប័ណ្ណ លិខិតឆ្លងដែន និងប័ណ្ណបើកបរ។ នៅក្នុងប្រទេសកម្ពុជា ពុំមានច្បាប់ដែលគាំទ្រដល់សិទ្ធិក្នុងការទទួលបានការទទួលស្គាល់តាមផ្លូវច្បាប់សម្រាប់ប្រជាជនដែលប្តូរយេនឌ័រ យោងទៅតាមយេនឌ័រដែលពួកគេកំណត់ដោយខ្លួនឯងនោះទេ។ ប៉ុន្តែ ក៏ពុំមានមាត្រាជាក់លាក់ណាមួយនៃច្បាប់ ដែលហាមឃាត់ការទទួលស្គាល់យេនឌ័រតាមផ្លូវច្បាប់នោះដែរ។ កង្វះនៃភាពច្បាស់លាស់ជុំវិញស្ថានភាពផ្លូវច្បាប់បច្ចុប្បន្ន បណ្តាលឱ្យប្រជាជនកម្ពុជាដែលប្តូរយេនឌ័រស្ថិតក្រោមការសម្រេចចិត្តជាលក្ខណៈបុគ្គលរបស់មន្ត្រីពាក់ព័ន្ធ។[23]

10. ទោះបីជាសិទ្ធិក្នុងការទទួលបានការទទួលស្គាល់យេនឌ័រតាមផ្លូវច្បាប់ មិនត្រូវបានកំណត់ច្បាស់លាស់ជាសិទ្ធិមួយប្រភេទដាច់ដោយឡែក នៅក្នុងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិណាមួយដែលកម្ពុជាជារដ្ឋភាគីក៏ដោយ ក៏ការទទួលបានសិទ្ធិនេះគឺជាការចាំបាច់ដើម្បីបំពេញសិទ្ធិមនុស្សជាមូលដ្ឋានដទៃទៀត សម្រាប់ប្រជាជនដែលប្តូរយេនឌ័រ ដែលកម្ពុជាមានកាតព្វកិច្ចដាក់លាក់ក្នុងការការពារ ដូចជា សិទ្ធិទទួលបានការទទួលស្គាល់នៅគ្រប់ទីកន្លែងក្នុងនាមជាមនុស្សស្មើភាពគ្នានៅចំពោះមុខច្បាប់[24] សិទ្ធិទទួលបានការអភិវឌ្ឍបុគ្គលិកលក្ខណៈដោយសេរី[25] និងសិទ្ធិរួចផុតពីការរើសអើង។[26]

11. ការទទួលស្គាល់តាមផ្លូវច្បាប់នូវអត្តសញ្ញាណយេនឌ័រដែលកំណត់ដោយខ្លួនឯង ក៏មានទំនាក់ទំនងដ៏ស្មុគស្មាញផងដែរទៅនឹងលទ្ធភាពក្នុងការបង្កើតជាគ្រួសារមួយ ការរៀបអាពាហ៍ពិពាហ៍ និងការសុំកូនចិញ្ចឹម ជាពិសេស នៅក្នុងប្រទេសកម្ពុជា ដែលបើតាមការស្ទង់មតិមួយដែលធ្វើឡើងដោយ ម.ស.ម.ក បានបង្ហាញថា ៩៩.១៧%នៃដៃគូ(គូស្រករ)អ្នកស្រឡាញ់ភេទដូចគ្នាដែលរស់នៅជាមួយគ្នា រួមមានដៃគូម្នាក់ដែលកំណត់អត្តសញ្ញាណខ្លួនឯងជាអ្នកប្តូរយេនឌ័រ និងម្នាក់ទៀតមិនមែនជាមនុស្សដែលប្តូរយេនឌ័រ។[27] ដូច្នេះ ការទទួលស្គាល់យេនឌ័រតាមផ្លូវច្បាប់ នឹងផ្តល់លទ្ធភាពដល់ប្តីប្រពន្ធស្រឡាញ់ភេទដូចគ្នាទាំងនេះជាច្រើនអាចរៀបការជាមួយគ្នា និងសុំកូនយកមកចិញ្ចឹម នៅក្រោមច្បាប់ជាធរមានស្រាប់ដែលគ្រប់គ្រងអាពាហ៍ពិពាហ៍និងការសុំកូនដោយមិនចាំបាច់តម្រូវឱ្យមានការធ្វើវិសោធនកម្មទៅលើច្បាប់អាពាហ៍ពិពាហ៍ ឬច្បាប់ស្តីពីការសុំកូនចិញ្ចឹមនោះឡើយ។

## *សមភាពអាពាហ៍ពិពាហ៍*

12. ការទទួលស្គាល់តាមផ្លូវច្បាប់នូវភាពជាដៃគូរបស់អ្នកស្រឡាញ់ភេទដូចគ្នា គឺមិនអាចធ្វើទៅបានឡើយនៅក្រោមប្រព័ន្ធច្បាប់បច្ចុប្បន្នរបស់កម្ពុជា។ រដ្ឋធម្មនុញ្ញកម្ពុជា នៅមាត្រា ៤៥ កំណត់ថា អាពាហ៍ពិពាហ៍ គឺរវាង «ប្តី» និង «ប្រពន្ធ» ដែលផាត់ចោលទាំងស្រុងនូវលទ្ធភាពសម្រាប់អាពាហ៍ពិពាហ៍រវាងមនុស្សភេទដូចគ្នា។[28] ប៉ុន្តែ អ្វីដែលជាការលើកទឹកចិត្ត គឺថា ការអនុម័តក្រមរដ្ឋប្បវេណីឆ្នាំ២០០៧និងច្បាប់ឆ្នាំ២០១១ ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី បានធ្វើនិរាករណ៍ចំពោះការហាមឃាត់អាពាហ៍ពិពាហ៍ភេទដូចគ្នាដែលមានពីមុន។[29] ខណៈដែលលែងមានការហាមឃាត់ផ្នែកច្បាប់ទៅលើអាពាហ៍ពិពាហ៍ភេទដូចគ្នា ក៏ពុំមានខចែងដាក់លាក់ណាមួយនៃច្បាប់ ដែលជួយសម្រួលដល់ការរៀបអាពាហ៍ពិពាហ៍ភេទដូចគ្នាដែរ។ ជាលទ្ធផល គេអាចរៀបចំពិធីរៀបការ និងពិធីជប់លៀងមិនផ្លូវការបាន ប៉ុន្តែ ការទទួលស្គាល់តាមផ្លូវច្បាប់នូវការរួមរស់ជាមួយគ្នារវាងអ្នកស្រឡាញ់ភេទដូចគ្នា គឺមិនអាចធ្វើទៅរួចឡើយ។ ច្បាប់ស្តីពីសិទ្ធិមនុស្សអន្តរជាតិ ពុំទាន់ទទួលស្គាល់ច្បាស់លាស់នូវសិទ្ធិនៃសមភាពអាពាហ៍ពិពាហ៍នៅឡើយទេ ប៉ុន្តែ ច្បាប់នេះពិតជាបានធានានូវការមិនរើសអើងចំពោះគ្រប់ទិដ្ឋភាពទាំងអស់នៃជីវិតរស់នៅរបស់មនុស្សគ្រប់រូបមែន។[30]

13. ប្ដីប្រពន្ធរស់នៅជាមួយគ្នា ដែលដៃគូទាំងពីរជាភេទដូចគ្នា ឬដែលដៃគូមួយ ឬដៃគូទាំងពីរកំណត់អត្តសញ្ញាណថាជាអ្នកប្តូរយេនឌ័រ («គ្រួសារឥន្ទធនូ») នៅទូទាំងប្រទេសកម្ពុជា គឺរួមរស់ជាមួយគ្នាក្នុងនាមជាដៃគូរួចជាស្រេចទៅហើយ ហើយពួកគេខ្លះថែមទាំងមានរៀបចំពិធីមង្គលការមិនផ្លូវការទៀតផង។[31] ទំនៀមទម្លាប់អាពាហ៍ពិពាហ៍ត្រូវបានឱ្យតម្លៃយ៉ាងពិសេស នៅក្នុងប្រទេសកម្ពុជា[32] ហើយការមិនរាប់បញ្ចូលប្រជាជន អ្នកស្រឡាញ់ភេទដូចគ្នាទៅក្នុងទំនៀមទម្លាប់អាពាហ៍ពិពាហ៍នេះ គឺមិនរាប់បញ្ចូលពួកគេក្នុងមូលដ្ឋានគ្រឹះដ៏សំខាន់បំផុតមួយនៃសង្គមកម្ពុជា។ ការស្ទង់មតិឆ្នាំ២០១៧ ទៅលើគ្រួសារឥន្ទធនូ បានបង្ហាញថា ២១.៥០% នៃពួកគេ ទទួលបាននូវការទទួលស្គាល់តាមផ្លូវច្បាប់ក្នុងទម្រង់ជាសៀវភៅគ្រួសារដែលចេញដោយអាជ្ញាធរមូលដ្ឋាន បើទោះបីជាខ្វះមូលដ្ឋានច្បាប់សម្រាប់ការទទួលស្គាល់បែបនេះក្តី។[33] សៀវភៅគ្រួសារជាច្រើនក្នុងចំណោមសៀវភៅគ្រួសារទាំងនេះ បញ្ចៀសការរឹតត្បិតផ្នែកច្បាប់ដោយចាត់ទុកដៃគូរួមរស់ជាមួយគ្នាជាគ្រួសារទាំងនេះ ថាជាប្តី និងប្រពន្ធ ឬជាបងប្អូនបង្កើតនឹងគ្នា។[34] ប៉ុន្តែនៅតាមខេត្តផ្សេងៗគ្នា មានភាពខុសគ្នាច្រើនពាក់ព័ន្ធនឹងការចេញសៀវភៅគ្រួសារដល់គ្រួសារឥន្ទធនូ ដែលបង្ហាញឱ្យឃើញនូវការបកស្រាយនិងការអនុវត្តច្បាប់មិនស៊ីសង្វាក់គ្នានៅថ្នាក់មូលដ្ឋាន។[35]

14. អ្វីដែលជាការលើកទឹកចិត្ត គឺថា គ្រួសារឥន្ទធនូភាគច្រើនបំផុតនៅក្នុងប្រទេសកម្ពុជា មានអារម្មណ៍គិតថាពួកគេត្រូវបានសហគមន៍របស់ខ្លួនយល់ព្រមទទួលយកកាន់តែច្រើនឡើងដោយមាន ៤៨.៦០% នៃអ្នកឆ្លើយតប នៅក្នុងការស្ទង់មតិរបស់ ម.ស.ម.ក បានថ្លែងថា សហគមន៍របស់ពួកគេ «មានការទទួលយកខ្លាំង» ចំពោះពួកគេក្នុងនាមពួកគេជាផ្នែកមួយនៃគ្រួសារឥន្ទធនូ និង ២៩.៩១% ទៀត « ទទួលយកខ្លះៗ»។[36] ភាគច្រើនលើសលប់នៃគ្រួសារឥន្ទធនូដែលបច្ចុប្បន្នកំពុងរួមរស់ជាមួយគ្នា (៨៧.៨៥% នៃអ្នកឆ្លើយតបនៅក្នុងការស្ទង់មតិរបស់ ម.ស.ម.ក) យល់ឃើញថា សមភាពអាពាហ៍ពិពាហ៍ គឺជាកត្តាដ៏សំខាន់ណាស់នៅក្នុងការកាត់បន្ថយការរើសអើងដែលនៅសេសសល់។[37]

15. ដោយសារតែគ្រួសារឥន្ទធនូមិនមានលទ្ធភាពរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់បាន សិទ្ធិនិងបុព្វសិទ្ធិជាច្រើនដែលកើតចេញពីអាពាហ៍ពិពាហ៍ស្របច្បាប់ ក៏ត្រូវបានបដិសេធផងដែរ ដូចជា ពាក់ព័ន្ធនឹងការកាន់កាប់អចលនទ្រព្យជាសហកម្មសិទ្ធិ ការគ្រប់គ្រងបីបាច់ថែរក្សាកូន ការបង់ពន្ធ ការផ្ទេរ ឬទទួលមរតក និងការការពារពីអំពើហិង្សាក្នុងគ្រួសារ។[38] ប៉ុន្តែមួយភាគធំនៃគ្រួសារឥន្ទធនូខ្វះការយល់ដឹងអំពីសិទ្ធិស្របច្បាប់របស់ខ្លួន ឬខ្វះការយល់ដឹងនៅក្នុងទិដ្ឋភាពទាំងនេះ ហើយជារឿយៗ ជឿជាក់ថា ពួកគេមានសិទ្ធិច្រើនជាងសិទ្ធិដែលខ្លួនមានជាក់ស្តែង ដែលនាំឱ្យពួកគេស្ថិតក្នុងស្ថានភាពងាយរងគ្រោះខ្លាំង។[39] កង្វះចំណេះដឹងផ្នែកច្បាប់នេះ មានន័យថាគ្រួសារឥន្ទធនូទំនងមិនសូវជាចាត់វិធានការដើម្បីកាត់បន្ថយកង្វះបុព្វសិទ្ធិ និងសិទ្ធិដែលផ្តល់ដល់ពួកគេឡើយ ដូចជា សិទ្ធិក្នុងការធ្វើលិខិតបណ្តាំមរតក។[40]

***ការសុំកូន***

16. ក្រមរដ្ឋប្បវេណីចែងថា «ការសុំកូនពេញលេញ» គឺសម្រាប់តែប្តីប្រពន្ធដែលបានអាពាហ៍ពិពាហ៍រួច ដែលនេះមានន័យថា បដិសេធសិទ្ធិសុំកូនពេញលេញចំពោះប្តីប្រពន្ធឥន្ទធនូ ដរាបណាសមភាពអាពាហ៍ពិពាហ៍នៅមិនទាន់មាន។[41] ក្រមរដ្ឋប្បវេណីក៏មានបញ្ញាក់ផងដែរ អំពីការសុំកូនមួយប្រភេទផ្សេងទៀត គឺ «ការសុំកូនធម្មតា» ដែលផ្តល់លទ្ធភាពដល់មនុស្សនៅលីវអាចសុំកូនចិញ្ចឹមបាន។[42] ជាទ្រឹស្តី ប្រការនេះអនុញ្ញាតឱ្យមនុស្សម្នាក់នៅក្នុងគ្រួសារឥន្ទធនូអាចសុំកូនចិញ្ចឹមបាន ក្នុងនាមប្តីប្រពន្ធ។ គ្រួសារឥន្ទធនូជាច្រើនដែលកំពុងរួមរស់ជាមួយគ្នាបច្ចុប្បន្ន នៅទូទាំងប្រទេសកម្ពុជា សុទ្ធតែមានកូនចិញ្ចឹមនៅក្នុងបន្ទុករបស់ពួកគេស្រាប់ទៅហើយ ដោយនៅក្នុង ៣២.៧១% នៃគ្រួសារឥន្ទធនូដែលបានស្ទង់មតិដោយ ម.ស.ម.ក (នៅឆ្នាំ ២០១៦) គឺមានដៃគូម្នាក់បានសុំកូនចិញ្ចឹម។[43] ជាងពីរភាគបីនៃការសុំកូនទាំងនេះ ធ្វើឡើងដោយផ្អែកទៅលើកិច្ចព្រមព្រៀង «សុំកូនធម្មតា» ឬកិច្ចព្រមព្រៀងមិនផ្លូវការ ហើយ ៤០% នៃប្តីប្រពន្ធឥន្ទធនូ បានសុំសមាជិកគ្រួសារ ដូចជា ក្មួយប្រុស ឬក្មួយស្រី យកមកចិញ្ចឹម។[44]

17. ប៉ុន្តែ នៅក្នុងការសុំកូនធម្មតា ដៃគូដែលមិនបានសុំកូនចិញ្ចឹមពុំមានការការពារផ្នែកច្បាប់ជាសារវន្តឡើយ ក្នុងករណីដែលដៃគូដែលសុំកូនចិញ្ចឹមទទួលមរណភាព ឬក្នុងករណីនៃការបញ្ចប់ទំនាក់ទំនង។ ជាងនេះទៅទៀត សិទ្ធិរបស់ឪពុក-ម្តាយចិញ្ចឹម នៅក្រោមការសុំកូនធម្មតា មិនមានការការពារផ្នែកច្បាប់ដូចគ្នានឹងការសុំកូនពេញលេញឡើយ។ ខុសពីការសុំកូនពេញលេញ ការសុំកូនធម្មតារក្សានូវទំនាក់ទំនងតាមផ្លូវច្បាប់រវាងកូន និងឪពុកម្តាយបង្កើតរបស់ពួកគេ ហើយមិនបង្កើតនូវឋានានុក្រមនៃសិទ្ធិណាមួយរវាងឪពុក-ម្តាយចិញ្ចឹម និងឪពុក-ម្តាយបង្កើតឡើយ[45] ដែលបង្កើតជាភាពមិនច្បាស់លាស់ផ្នែកច្បាប់ និងភាពងាយរងគ្រោះចំពោះឪពុក-ម្តាយចិញ្ចឹម។

18. អនុសញ្ញាស្តីពីសិទ្ធិកុមារ ("CRC") ដែលកម្ពុជាក៏ជារដ្ឋភាគីមួយនៃអនុសញ្ញានេះដែរ ចែងថា *«រដ្ឋភាគីត្រូវចាត់ការស្របទៅតាមច្បាប់ជាតិរបស់ខ្លួន ដើម្បីធានាការថែទាំជំនួស»* ដល់កុមារដែលបាត់បង់បរិយាកាសគ្រួសារជាបណ្តោះអាសន្ន ឬជាអចិន្ត្រៃយ៍[46] និងចែងថា នៅក្នុងប្រព័ន្ធសុំកូន ការពិចារណាសំខាន់បំផុតត្រូវគិតទៅលើ *«ឧត្តមប្រយោជន៍របស់កុមារ»*[47]។ នៅក្នុងប្រទេសកម្ពុជា កុមារប្រហែលម្នាក់ក្នុងចំណោម ១០០ នាក់ រស់នៅក្នុងមណ្ឌលថែទាំ[48] ហើយថ្មីៗនេះ រាជរដ្ឋាភិបាលកម្ពុជា បានប្តេជ្ញាកាត់បន្ថយចំនួនកុមារដែលរស់នៅតាមមណ្ឌលថែទាំ។[49] ការបង្កើតនូវសិទ្ធិសុំកូនពេញលេញសម្រាប់គ្រួសារឥន្ទធនូ អាចចូលរួមចំណែកបានខ្លះនៅក្នុងការធានាថា កុមារកម្ពុជាគ្រប់រូបត្រូវបានផ្តល់នូវបរិយាកាសគ្រួសារដែលប្រកបដោយក្តីស្រឡាញ់ និងការការពារ ដែលគាំទ្រដល់ការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាល និងគោលការណ៍ *«មិនទុកអ្នកណាម្នាក់ចោល»*[50] នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

## អនុសាសន៍

i. ដាក់ចេញនូវច្បាប់ប្រឆាំងការរើសអើង នៅត្រឹមដំណាច់ឆ្នាំ២០២៣ ដែលធានាសមភាព និងហាមឃាត់ច្បាស់លាស់នូវការរើសអើងគ្រប់ប្រភេទ ក្នុងនោះរាប់ទាំងការរើសអើងដោយសារ និន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញលក្ខណៈភេទ នៅក្នុងគ្រប់ទិដ្ឋភាពនៃជីវភាពសាធារណៈ និងជីវភាពឯកជន ដោយរាប់បញ្ចូលទាំងនៅក្នុងវិស័យការងារ ការអប់រំ និងការទទួលបានការថែទាំសុខភាព ពីសំណាក់តួអង្គឯកជន និងរដ្ឋទាំងអស់ស្របទៅតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ៥.១.។

ii. កំណត់អំពី និងដាក់បញ្ចូលបទល្មើសនៃ «អំពើស្អប់ខ្ពើម» ទៅក្នុងក្រមព្រហ្មទណ្ឌ នៅត្រឹមដំណាច់ឆ្នាំ ២០២៣ ដោយស្របទៅតាមទម្លាប់អនុវត្តន៍ជាអន្តរជាតិ ក្នុងនោះរាប់បញ្ចូលទាំងទោសទណ្ឌសមស្របចំពោះជនល្មើសដែលបានប្រព្រឹត្តបទល្មើសស្អប់ខ្ពើមទៅលើប្រជាជន អ្នកស្រឡាញ់ភេទដូចគ្នា និងប្រជាជនក្រុមភាគតិចដទៃទៀត ស្របទៅតាម គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ៥.១, ៥.២, ១៦.១ និង ១៦.២[51]។

iii. ដាក់ចេញនូវច្បាប់ទទួលស្គាល់យេនឌ័រ នៅត្រឹមដំណាច់ឆ្នាំ២០២១ ដែលធានាដល់ប្រជាជនគ្រប់រូបនូវសិទ្ធិទទួលបានការទទួលស្គាល់អត្តសញ្ញាណយេនឌ័រដែលកំណត់ដោយខ្លួនឯង នៅលើគ្រប់ឯកសារផ្លូវការ ដែលចេញដោយរដ្ឋ (ដូចជា អត្តសញ្ញាណប័ណ្ណ សៀវភៅគ្រួសារ លិខិតឆ្លងដែន ។ល។) តាមរយៈនីតិវិធីរដ្ឋបាលសាមញ្ញមួយដោយផ្អែកលើការកំណត់ដោយខ្លួនឯង។

iv. ធ្វើវិសោធនកម្មមាត្រា ៤៥ នៃរដ្ឋធម្មនុញ្ញ ដើម្បីផ្តល់លទ្ធភាពដល់សមភាពអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ នៅត្រឹមដំណាច់ឆ្នាំ២០២២ និងធានាថា មនុស្សពេញវ័យពីរនាក់ណាក៏បានដែលមានការព្រមព្រៀងគ្នាអាចរៀបអាពាហ៍ពិពាហ៍ជាមួយគ្នាបាន ក្នុងលក្ខណៈដូចគ្នានឹងគូស្រករភេទផ្ទុយគ្នាដែរ។

v. ធ្វើវិសោធនកម្មបញ្ញត្តិពាក់ព័ន្ធនៃក្រមរដ្ឋប្បវេណី (មាត្រា ១០០៨-១០១៥) ដែលគ្រប់គ្រងការសុំកូន ដើម្បីធានាថា សិទ្ធិសុំកូនពេញលេញត្រូវបានផ្តល់ដល់ដៃគូណាក៏ដោយ ឲ្យតែគេអាចបង្ហាញថា ការសុំកូននោះគឺដើម្បី*«ឧត្តមប្រយោជន៍របស់កុមារ»* ដោយគ្មានការរើសអើង ផ្អែកលើមូលដ្ឋាន និន្នាការភេទ អត្តសញ្ញាណយេនឌ័ និងការបង្ហាញលក្ខណៈភេទ ឬស្ថានភាពណាមួយផ្សេងទៀត នៅត្រឹមដំណាច់ឆ្នាំ២០២១។

vi. ចេញសារាចរណែនាំ ដែលចែងច្បាស់លាស់អំពីសិទ្ធិរបស់គ្រួសារឥន្ទធនូទាំងអស់ក្នុងការទទួលបានសៀវភៅគ្រួសារ ដែលបញ្ជាក់យេនឌ័ររបស់ពួកគេទៅតាមអត្តសញ្ញាណយេនឌ័រដែលកំណត់ដោយខ្លួនឯង និងទំនាក់ទំនងគ្រួសារជាក់ស្តែងនៅត្រឹមដំណាច់ឆ្នាំ២០២១។

### 3. ការរើសអើងផ្នែកសង្គមទៅលើប្រជាជន អ្នកស្រឡាញ់ភេទដូចគ្នា [52]

19. ទោះបីជាសហគមន៍ អ្នកស្រឡាញ់ភេទដូចគ្នា នៅកម្ពុជាពិតជាទទួលបានការបង្ហាញចេញកាន់តែច្រើនឡើង មួយផ្នែកដោយសារចលនាទាមទារសិទ្ធិ អ្នកស្រឡាញ់ភេទដូចគ្នា កើនឡើង និងបរិបទមួយដែលមិនសូវមានការជំទាស់ខ្លាំងក្លាផ្នែកសាសនា ឬផ្នែកស្ថាប័ន[53] ក៏ដោយ ក៏ប្រជាជន អ្នកស្រឡាញ់ភេទដូចគ្នា នៅក្នុងប្រទេសកម្ពុជានៅតែទទួលរងការរើសអើងជាបន្ត និងត្រូវបានផាត់ចេញពីវិស័យជាច្រើននៃជីវភាពសង្គម។[54] ផ្នែកនេះពិនិត្យទៅលើការយល់ឃើញជាទូទៅរបស់ប្រជាជន អ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា និងបង្ហាញពីទម្រង់ជាក់លាក់មួយចំនួននៃការរើសអើងផ្នែកសង្គម និងការមិនរាប់បញ្ចូលប្រជាជន អ្នកស្រឡាញ់ភេទដូចគ្នា ក្នុងបរិយាកាសគ្រួសារ និងសាលារៀន ព្រមទាំងវិសាលភាពនៃអំពើហិង្សា ផ្អែកលើយេនឌ័រ ("GBV") ដែលប្រព្រឹត្តទៅលើប្រជាជន អ្នកស្រឡាញ់ភេទដូចគ្នា ។ ទម្រង់នៃការរើសអើងទាំងនេះ និងការមិនរាប់បញ្ចូលក្នុងបរិយាកាសសង្គម ជះផលវិបាកយ៉ាងច្រើនគួរឱ្យកត់សម្គាល់ទៅលើជីវិតរស់នៅរបស់ប្រជាជន អ្នកស្រឡាញ់ភេទដូចគ្នា និងធ្វើឱ្យស្ថានភាពវិសមភាពនៅតែមានជាបន្ត។ ជាងនេះទៅទៀត វាជាទំនួលខុសត្រូវរបស់ រាជរដ្ឋាភិបាលកម្ពុជា ក្នុងការដាក់ឱ្យអនុវត្តនូវគោលនយោបាយនានា ដែលធានាថា ការគាំពារផ្នែកសង្គមកិច្ច និងបរិយាប័ន្នសម្រាប់ប្រជាជន អ្នកស្រឡាញ់ភេទដូចគ្នាដើម្បីឱ្យសិទ្ធិមនុស្សរបស់ពួកគេអាចសម្រេចបាន និងទទួលបានការការពារ។

## *ការរើសអើងពីសំណាក់សមាជិកគ្រួសារ*

20. ទោះបីមានការទទួលស្គាល់កើនឡើងពីសំណាក់សហគមន៍របស់ពួកគេក្តី ប្រជាជនអ្នកស្រឡាញ់ភេទដូចគ្នា នៅកម្ពុជា នៅតែប្រឈមនឹងការមិនរាប់បញ្ចូលក្នុងគ្រួសាររបស់ខ្លួនក្នុងកម្រិតខ្ពស់ដដែល។ នៅក្នុងការស្ទង់មតិទូទាំងប្រទេសមួយកាលពីឆ្នាំ២០១៥ រ៉ក់ បានរកឃើញថា ប្រជាជនអ្នកស្រឡាញ់ភេទដូចគ្នា រឹតត្បិតការចេញមុខមាត់របស់ពួកគេតែជាមួយមិត្តភក្តិជិតស្និទ្ធ (៧៧%) និងសមាជិកគ្រួសារញាតិខ្សែផ្ទាល់ (៥៤%) ដោយសារការភ័យខ្លាចនៃការរើសអើង ការពេបជ្រាយ ការបង្អាប់ និងការបៀតបៀន នៅក្នុងជីវិតរស់នៅប្រចាំថ្ងៃរបស់ខ្លួន។[55] ការស្ទង់មតិដដែលក៏បានបង្ហាញដែរថា ស្ទើរតែមួយភាគបីនៃប្រជាជនអ្នកស្រឡាញ់ភេទដូចគ្នា មិនដែល «ចេញមុខជាចំហរ» (២៩%) និងជាងមួយភាគប្រាំនៃអ្នកផ្តល់ចម្លើយដែលជាអ្នកស្រលាញ់ភេទដូចគ្នា (២១%) បានផ្តល់ចម្លើយថា បើអាចពួកគេប្រាថ្នាជាអ្នកស្រលាញ់ភេទផ្ទុយគ្នា[56]

21. ស្ទើរតែមួយភាគប្រាំនៃឪពុកម្តាយភេទផ្ទុយគ្នាដែលបានសម្ភាសនៅក្នុងការស្ទង់មតិរបស់ រ៉ក់ (១៧%) បាននិយាយថា ពួកគេនឹងបង្ខំកូនឱ្យស្រឡាញ់ភេទផ្ទុយគ្នា និងនៅទីបំផុត អាចនឹងបង្ខំឱ្យពួកគេរៀបការ ដោយមិនខ្វល់នឹងការពិតដែលថា អាពាហ៍ពិពាហ៍ដោយបង្ខំនោះគឺជាការបំពានរដ្ឋធម្មនុញ្ញក៏ដោយ។[57] នៅក្នុងការស្ទង់មតិមួយជាមួយអ្នកប្តូរយេនឌ័រពីបុរសទៅស្ត្រីនៅតំបន់ទីប្រជុំជន កាលពីឆ្នាំ២០១៦ ជាងពាក់កណ្តាលនៃអ្នកឆ្លើយតប (៥៣.៤៩%) បាននិយាយថា មានសមាជិកគ្រួសារម្នាក់បានព្យាយាមបង្ខំពួកគេ

ឱ្យរៀបអាពាហ៍ពិពាហ៍កាលពីពេលកន្លងមក។[58] ការស្ទង់មតិនេះក៏បានបង្ហាញដែរថា ៤៨.៨៥% នៃអ្នកឆ្លើយតប មានអារម្មណ៍ថា ពួកគេចាំបាច់ត្រូវតែចាកចេញពីផ្ទះដោយសារតែអត្តសញ្ញាណយេនឌ័ររបស់ខ្លួន និងថា ១៥.២៧% នៅក្រាមួយ ត្រូវបានគ្រួសារបណ្តេញចេញពីផ្ទះ ដែលនេះបញ្ជាក់អំពីវិសាលភាពនៃការមិនរាប់បញ្ចូលក្នុងគ្រួសារដោយសារតែអត្តសញ្ញាណយេនឌ័រ។[59]

## ការយល់ឃើញរបស់សាធារណជនអំពីប្រជាជនអ្នកស្រលាញ់ភេទដូចគ្នា

22. រាជរដ្ឋាភិបាលកម្ពុជា បានចាត់វិធានការមួយចំនួនដើម្បីដោះស្រាយអំពីបញ្ហាប្រជាជន អ្នកស្រឡាញ់ភេទដូចគ្នា នៅតាមបណ្តាញសារព័ត៌មាន។ កាលពីឆ្នាំ២០១៥ ក្រសួងព័ត៌មានបានចេញសេចក្តីថ្លែងការណ៍មួយ អំពាវនាវឱ្យសមាជិកនៃបណ្តាញសារព័ត៌មានបញ្ឈប់ការចំអកចំអន់ដាក់សហគមន៍ អ្នកស្រឡាញ់ភេទដូចគ្នា។[60] នៅឆ្នាំដដែលនោះ បន្ទាប់ពីពិភាក្សាជាមួយសកម្មជន អ្នកស្រឡាញ់ភេទដូចគ្នា រដ្ឋមន្រ្តីក្រសួងព័ត៌មាន ខៀវ កាញារីទ្ធ បានសម្តែងការគាំទ្រឱ្យមានកិច្ចពិភាក្សាតុមូលអំពី អ្នកស្រឡាញ់ភេទដូចគ្នា ចាក់ផ្សាយតាមប៉ុស្តិ៍ទូរទស្សន៍រដ្ឋ។[61] នៅឆ្នាំ២០១៧ រដ្ឋមន្ត្រីក្រសួងព័ត៌មានក៏បានប្រកាសពីការបង្កើតគណៈកម្មាធិការមួយដើម្បីសង្កេត និងទទួលពាក្យបណ្តឹងពីទូរទស្សនិកជន ដែលបានឃើញខ្លឹមសាររើសអើងនៅលើបណ្តាញព័ត៌មាន។[62]

23. ការប្រារព្ធទិវាមោទនភាពត្រូវបានរៀបចំឡើងនៅក្នុងប្រទេសកម្ពុជា ចាប់តាំងពីឆ្នាំ២០០៩ មកម្ល៉េះ ដោយមានការផ្សព្វផ្សាយ និងការចូលរួមកាន់តែច្រើនឡើងៗ។[63] ទោះបីជាដូច្នេះក្តី ការរើសអើង និងការមិនរាប់បញ្ចូលជាហូរហែ បានបន្តបន្ទច់បង្អាក់ដល់ការទទួលបានសិទ្ធិពេញលេញរបស់ប្រជាជនអ្នកស្រឡាញ់ភេទដូចគ្នា។[64]

24. ការស្ទង់មតិឆ្នាំ២០១៧ របស់ ម.ស.ម.ក បង្ហាញថា គ្រួសារឥន្ទធនូរាយការណ៍ឱ្យដឹងពីកម្រិតខ្ពស់នៃការទទួលស្គាល់ពីសំណាក់សហគមន៍របស់ពួកគេ។[65] អ្នកឆ្លើយនឹងការស្ទង់មតិជាច្រើន បានរាយការណ៍អំពីការល្អប្រសើរឡើងនៃការទទួលស្គាល់នេះ ដោយសារតែចលនាទាមទារសិទ្ធិរបស់ អ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា កាន់តែមានភាពលេចធ្លោ។ នេះមានន័យថា ការជឿនលឿនបន្ថែមទៀតនៃការទទួលស្គាល់ផ្នែកច្បាប់ចំពោះសិទ្ធិ អ្នកស្រឡាញ់ភេទដូចគ្នា អាចនាំទៅរកការកើនឡើងនូវកម្រិតនៃការទទួលស្គាល់ ការដាក់បញ្ចូល និងការយល់ដឹងអំពី និន្នាការភេទ អត្តសញ្ញាណយេនឌ័រនិងការបង្ហាញលក្ខណៈភេទ នៅក្នុងប្រទេសកម្ពុជា។[66]

## ការធ្វើបាប (ចំអកសម្លុត) និងការមិនរាប់បញ្ចូលនៅតាមសាលារៀន

25. ការស្ទង់មតិមួយទៅលើយុវជន អ្នកស្រឡាញ់ភេទដូចគ្នាដែលបានធ្វើឡើងដោយ ម.ស.ម.ក កាលពីឆ្នាំ ២០១៥បានបង្ហាញថា ៦២.៧១% នៃអ្នកឆ្លើយតប ធ្លាប់ទទួលរងការធ្វើបាបនៅពេលរៀននៅសាលា និង ៩៣.៥៩% នៃពួកគេ មានអារម្មណ៍ថា ការធ្វើបាបនេះគឺដោយអន្លើ ឬទាំងស្រុង បណ្តាលមកពី និន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញលក្ខណៈភេទ របស់ពួកគេ។[67] ការធ្វើបាបដែលទាក់ទងនឹងនិន្នាការភេទ អត្តសញ្ញាណយេនឌ័រនិងការបង្ហាញលក្ខណៈភេទ អាចមានផលប៉ះពាល់ទៅលើសក្តានុពលផ្នែកការសិក្សារបស់យុវជន អ្នកស្រឡាញ់ភេទដូចគ្នាជាច្រើននាក់នៅក្នុងប្រទេសកម្ពុជា ហើយក៏ប៉ះពាល់ធ្ងន់ធ្ងរទៅលើសុខុមាលភាព មនោសញ្ចេតនា និងផ្លូវចិត្តរបស់ពួកគេផងដែរ។[68] ក្រៅពីទម្រង់ដទៃទៀតនៃការយាយី គោលការណ៍ស្លៀកពាក់ឯកសណ្ឋានបែងចែកតាមភេទ ធ្វើឱ្យកុមារ អ្នកស្រឡាញ់ភេទដូចគ្នាមានអារម្មណ៍ថា មិនស្រណុកក្នុងចិត្ត។ ឧទាហរណ៍ ជាងមួយភាគបួននៃអ្នកចូលរួម (២៦.៨៩%) នៅក្នុងការស្ទង់មតិរបស់ ម.ស.ម.ក បាននិយាយថា គ្រូរបស់ពួកគេពិតជាបានអនុវត្តគោលនយោបាយឯកសណ្ឋានដែលធ្វើឱ្យពួកគេមានអារម្មណ៍មិនស្រួលចិត្ត ហើយចំនួននេះបានកើនឡើងដល់ ៤០.៤៨% ក្នុងចំណោមអ្នកចូលរួមធ្វើការស្ទង់មតិ ដែលផ្តល់អត្តសញ្ញាណខ្លួនឯងថាជា អ្នកប្តូរយេនឌ័រ[69]

26. រាជរដ្ឋាភិបាលកម្ពុជា បានចាត់វិធានការវិជ្ជមាន និងគួរឱ្យកត់សម្គាល់មួយចំនួន ដើម្បីដោះស្រាយបញ្ហានៃការចំអកសម្លុតមកលើកុមារ អ្នកស្រឡាញ់ភេទដូចគ្នា នៅតាមសាលារៀន។ នៅឆ្នាំ២០១៥ ក្រសួងអប់រំ យុវជន និងកីឡា ("MOEYS") បានចាប់ដៃគូជាមួយអង្គការក្រៅរដ្ឋាភិបាល ដើម្បីធ្វើការបណ្តុះបណ្តាលបញ្ជ្រាបការយល់ដឹងសម្រាប់គ្រូ ដើម្បីប្រយុទ្ធប្រឆាំងការចំអកសម្លុតមកលើយុវជន អ្នកស្រឡាញ់ភេទដូចគ្នា ។[70] លើសពីនេះទៀត ក្រសួងអប់រំយុវជននិងកីឡា សហការជាដៃគូជាមួយអង្គការក្រៅរដ្ឋាភិបាល បានរៀបចំតាក់តែងកម្មវិធីសិក្សា «បំណិនជីវិត» ថ្មី កាលពីឆ្នាំ២០១៧ ដែលផ្តល់ការបង្រៀនដែលមានបរិយាប័ន្ន អំពីបញ្ហាអ្នកស្រឡាញ់ភេទដូចគ្នា ការអប់រំផ្លូវភេទ និងអំពើហិង្សាលើយេនឌ័រ ។[71] សៀវភៅមេរៀនថ្មីនេះ មានគោលបំណងឱ្យគេដាក់បញ្ចូលជាផ្នែកមួយ នៃកម្មវិធីសិក្សាដែលតម្រូវដោយច្បាប់ នៅតាមសាលារៀនរដ្ឋ និងគ្រោងនឹងដាក់ឱ្យអនុវត្តនៅទូទាំងប្រទេស នៅឆ្នាំ២០២៣ (សូមមើលសេចក្តីលម្អិតបន្ថែមនៅត្រង់ផ្នែកទី៧)។

27. កម្ពុជាគឺជាភាគីមួយនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ (CRC) ដែលចែងអំពីសិទ្ធិទទួលបានការអប់រំ[72] និងមាន ខ ចែងអំពីការមិនរើសអើង ដែលត្រូវបានបកស្រាយដោយគណៈកម្មាធិការសិទ្ធិកុមារថា រួមបញ្ចូលទាំងការហាមឃាត់ការរើសអើងលើ អ្នកស្រឡាញ់ភេទដូចគ្នាផងដែរ។[73] ទោះបីមិនភ្ជាប់កាតព្វកិច្ចអនុវត្តក្តី គោលការណ៍យ៉កយ៉ាហ្កាតា (Yogyakarta) លេខ ១៦ ចែងថា *«មនុស្សគ្រប់រូបមានសិទ្ធិទទួលបានការអប់រំដោយគ្មានការរើសអើង និងដោយមិនគិតអំពីនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័ររបស់ពួកគេឡើយ»* និងយោងទៅតាមអត្ថិភាពនៃកាតព្វកិច្ចវិជ្ជមានទាំងប្រាំពីរ ដែលតម្រូវឱ្យរដ្ឋភាគីចាត់វិធានការផ្នែកច្បាប់ដែលសំដៅលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងប្រជាជនអ្នកស្រឡាញ់ភេទដូចគ្នានៅក្នុងប្រព័ន្ធ

អប់រំ ក្នុងនោះរាប់បញ្ចូលទាំងការបង្កើតគោលនយោបាយ និងច្បាប់នានា ដើម្បីប្រយុទ្ធប្រឆាំងនឹងការចំអកសម្លុតដោយផ្អែកលើមូលដ្ឋាន និន្នាការភេទ អត្តសញ្ញាណយេនឌ័រនិងការបង្ហាញលក្ខណៈ។[74]

### *អំពើហិង្សាផ្អែកលើយេនឌ័រ*

28. ទោះបីកម្ពុជាមិនបានទទួលអនុសាសន៍ជាក់លាក់ណាមួយស្តីពី និន្នាការភេទ អត្តសញ្ញាណយេនឌ័រនិងការបង្ហាញលក្ខណៈផ្លូវភេទ និងសិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា ក្នុងអំឡុងពេល UPR លើកទីពីររបស់ខ្លួនក្តី ក៏រាជរដ្ឋាភិបាលកម្ពុជា បានទទួលអនុសាសន៍ចំនួនពីរ ស្តីពីសមភាពយេនឌ័រ និងការរើសអើង និងអំពើហិង្សាផ្អែកលើយេនឌ័រ ដែលក៏ពាក់ព័ន្ធផងដែរទៅនឹងបុគ្គល អ្នកស្រឡាញ់ភេទដូចគ្នា ។[75]

29. នៅឆ្នាំ២០១៤ ផែនការយុទ្ធសាស្រ្ត ៥ឆ្នាំ របស់ក្រសួងកិច្ចការនារី បានកត់សម្គាល់ថា ស្ត្រីស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរយេនឌ័រ គឺស្ថិតក្នុងចំណោមក្រុមមនុស្សដែលងាយរងគ្រោះបំផុតនៅក្នុងសង្គម ដោយពួកគេប្រឈមមុខនឹងហានិភ័យខ្ពស់នៃការរើសអើង ការមាក់ងាយ និង អំពើហិង្សាលើយេនឌ័រ។[76] ទោះបីមានការទទួលស្គាល់បែបនេះពីសំណាក់ រាជរដ្ឋាភិបាលកម្ពុជា ក្តី ក៏ប្រជាជនអ្នកស្រឡាញ់ភេទដូចគ្នា នៅកម្ពុជានៅតែប្រឈមនឹង អំពើហិង្សាលើយេនឌ័រ (GBV) កម្រិតខ្ពស់ដដែល ដែលប៉ះពាល់ជាពិសេសទៅលើអ្នកប្តូរយេនឌ័រពីបុរសទៅស្ត្រី។

30. នៅក្នុងការស្ទង់មតិឆ្នាំ២០១៦ ដែលធ្វើឡើងដោយ ម.ស.ម.ក អ្នកប្តូរយេនឌ័រពីបុរសទៅស្ត្រីស្ទើរតែទាំងអស់ដែលបានចូលរួមនៅក្នុងការស្ទង់មតិ បានរាយការណ៍ថា ធ្លាប់ទទួលរងនូវការបៀតបៀននៅខណៈពេលដែលស្ថិតនៅតាមទីសាធារណៈដោយសារតែអត្តសញ្ញាណប្តូរយេនឌ័ររបស់ខ្លួន ដែលក្នុងករណីខ្លះជួបប្រទះជាច្រើនលើកច្រើនសារក្នុងអំឡុងពេលមួយឆ្នាំ។[77] ៩២% នៃអ្នកប្តូរយេនឌ័រពីបុរសទៅស្ត្រីដែលបានស្ទង់មតិ ធ្លាប់ទទួលរងការបំពានតាមរយៈពាក្យសម្តី ៤៣% ធ្លាប់ទទួលរងអំពើហិង្សាលើរាងកាយ ៣១% ធ្លាប់ទទួលរងការបំពានផ្លូវភេទ និង ២៥% ធ្លាប់ត្រូវបានគេរំលោភសេពសន្ថវៈ។[78] ស្រដៀងគ្នានេះការសិក្សាមួយកាលពីឆ្នាំ២០១៦ ដែលធ្វើឡើងដោយមជ្ឈមណ្ឌលជាតិប្រយុទ្ធប្រឆាំងនឹងមេរោគអេដស៍/ជំងឺ អេដស៍ ជំងឺសើស្បែក និងកាមរោគ ("NCHADS") បានបង្ហាញថា ៣៩.២% នៃអ្នកប្តូរយេនឌ័រពីបុរសទៅស្ត្រីបានរាយការណ៍ថា ធ្លាប់ត្រូវបានគេបំពានផ្លូវភេទ ហើយ ២៣.៦% បានរាយការណ៍ថា ធ្លាប់ត្រូវបានគេបំពានរាងកាយ ឬការវាយដំ។[79]

31. ជាងនេះទៅទៀត ៣៨.៧% នៃអ្នកប្តូរយេនឌ័រពីបុរសទៅស្ត្រី ដែលស្ទង់មតិដោយ ម.ស.ម.ក ធ្លាប់ត្រូវបាននគរបាលចាប់ខ្លួនយ៉ាងហោចណាស់មួយលើក ដោយក្នុងនោះ ៩១.៦៧% ជឿជាក់ថា នគរបាលចាប់ខ្លួនពួកគេដោយសារតែអត្តសញ្ញាណយេនឌ័ររបស់ពួកគេ និង ៣៣.៥៨% បានរាយការណ៍ថា ធ្លាប់ត្រូវបាន

ចោទប្រកាន់ពីបទល្មើសមួយដែលខុសពីការពិត។[80] ជាងនេះទៅទៀត ការសិក្សារបស់ ម.ស.ម.ក បាន បង្ហាញឱ្យឃើញថា អ្នកប្ដូរយេនឌ័រពីបុរសទៅស្ត្រីដែលធ្វើការជាស្ត្រីប្រកបរបរសេវាផ្លូវភេទ ជួបប្រទះការ បៀតបៀនពីសំណាក់នគរបាលច្រើនជាងគេ បើធៀបនឹងអ្នកប្ដូរយេនឌ័រពីបុរសទៅស្ត្រីដែលមិនធ្វើការជា ស្ត្រីប្រកបរបរសេវា ផ្លូវភេទ ដោយមាន ៥៨.៣៣% នៃអ្នកប្ដូរយេនឌ័រពីបុរសទៅស្ត្រីដែលធ្វើការជាស្ត្រី ប្រកបរបរសេវាផ្លូវភេទ បានរាយការណ៍ថា ធ្លាប់ទទួលរងការបៀតបៀន ឬការធ្វើបាបពីសំណាក់នគរបាល ដោយសារតែពួកគេជាអ្នកប្ដូរយេនឌ័រ និង ៤៦.៩៤% នៃស្ត្រីប្រកបរបរសេវាផ្លូវភេទ រាយការណ៍ថា ធ្លាប់ត្រូវ នគរបាលចោទប្រកាន់ខុសពីការពិតថា បានប្រព្រឹត្តបទល្មើស បើធៀបនឹង ២៥.៨៨% នៃអ្នកប្ដូរយេនឌ័រពី បុរសទៅស្ត្រីដែលមិនធ្វើការជាស្ត្រីប្រកបរបរសេវាផ្លូវភេទ។[81]

### អនុសាសន៍

4. ដាក់ចេញនូវគោលនយោបាយជាក់លាក់នៃការមិនរើសអើងផ្អែកលើ និន្នាការភេទ អត្តសញ្ញាណ យេនឌ័រ និងការបង្ហាញលក្ខណៈភេទនៅក្នុងវិស័យសេវាសាធារណៈទាំងមូលនៅប្រទេសកម្ពុជា ដោយ ផ្ដោតជាអាទិភាពនៅក្នុងប្រព័ន្ធអប់រំ (ស្របជាមួយនឹងគោលដៅអភិវឌ្ឍប្រកបដោយចីរភាពទី៤) វិស័យសុខាភិបាល (ស្របនឹងគោលដៅអភិវឌ្ឍប្រកបដោយចីរភាពទី៣) នៅក្នុងបណ្ដាញសារ ព័ត៌មាន និងនៅតាមស្ថាប័ននគរបាលនៅថ្នាក់មូលដ្ឋាន និងនៅថ្នាក់ជាតិ (ស្របនឹង គោលដៅអភិវឌ្ឍ ប្រកបដោយចីរភាពទី ១) នៅត្រឹមឆ្នាំ២០២០ និងអនុវត្តជាបន្តនូវគំនិតផ្ដួចផ្ដើមលើកកម្ពស់ការយល់ ដឹងបែបសកម្ម ដើម្បីបង្កើនការយល់ដឹងអំពីសិទ្ធិ អ្នកស្រឡាញ់ភេទដូចគ្នា ក្នុងចំណោមសាធារណជន ទូទៅ និងមន្ត្រីរដ្ឋាភិបាល។

5. បង្កើតយន្តការគាំពារកុមារនៅតាមសាលារៀន ដើម្បីធានាថា ពួកគេមានសមត្ថភាពតាមដាន និងឆ្លើយ តបទៅនឹងការរើសអើង និងអំពើហិង្សាផ្អែកលើ និន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញ លក្ខណៈភេទ នៅមុនឆ្នាំ២០២០។

6. ធានាថា សិស្សានុសិស្សគ្រប់រូបត្រូវបានអនុញ្ញាតឱ្យជ្រើសរើសស្លៀកពាក់ឯកសណ្ឋានសាលាដែល ស្របទៅនឹងអត្តសញ្ញាណយេនឌ័រដែលគាត់កំណត់ដោយខ្លួនឯង ទាំងនៅក្នុងប្រព័ន្ធអប់រំរដ្ឋ និងប្រព័ន្ធ អប់រំឯកជន នៅឆ្នាំ២០២០។

## 4. ឱកាសការងារ និងស្ថានភាពសេដ្ឋកិច្ចរបស់ប្រជាជនអ្នកស្រលាញ់ភេទដូចគ្នា

32. ប្រជាជនអ្នកស្រឡាញ់ភេទដូចគ្នា នៅប្រទេសកម្ពុជា ប្រឈមនឹងការរើសអើងនៅក្នុងការទទួលបាន និង រក្សាការងារ ព្រមទាំងការរើសអើង និងការមិនរាប់បញ្ចូលនៅក្នុងកន្លែងធ្វើការ។ ផ្នែកនេះក៏ពិនិត្យផងដែរ ទៅ

លើស្ថានភាពសេដ្ឋកិច្ចរបស់ប្រជាជន អ្នកស្រឡាញ់ភេទដូចគ្នាព្រមទាំងផ្នត់គំនិតសង្គម និងការរើសអើង ដែលទទួលរងដោយ អ្នកស្រឡាញ់ភេទដូចគ្នាដែលប្រកបរបរសេវាផ្លូវភេទ។

## ការរើសអើងក្នុងការទទួលបានការងារ និងការរើសអើងនៅកន្លែងធ្វើការ

33. មាត្រា ១២ នៃច្បាប់ការងាររបស់ប្រទេសកម្ពុជា មានចែងនូវបទប្បញ្ញត្តិស្តីពីការមិនរើសអើងនៅកន្លែងការងារ ប៉ុន្តែ មិនបានទទួលស្គាល់ពី និន្នាការភេទ អត្តសញ្ញាណយេនឌ័រនិងការបង្ហាញលក្ខណៈភេទ ជាមូលដ្ឋានសម្រាប់ការមិនរើសអើងឡើយ។[82] មាត្រា ៦ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ ("ក.អ.ស.ស.អ") ដែលកម្ពុជាគឺជារដ្ឋភាគីមួយដែរក្នុងការទទួលស្គាល់ «សិទ្ធិធ្វើការងារ»[83] ហើយគណៈកម្មាធិការសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ របស់អង្គការសហប្រជាជាតិ បានបកស្រាយច្បាស់លាស់ថា សិទ្ធិនេះមានន័យថា ទីផ្សារការងារគួរតែបើកចំហសម្រាប់មនុស្សគ្រប់រូប ដោយគ្មានការរើសអើង ក្នុងនោះរាប់បញ្ចូលទាំងការរើសអើងផ្អែកលើនិន្នាការភេទផងដែរ។[84] ជាងនេះទៅទៀត យោងតាមមាត្រា 2 នៃ ("ក.អ.ស.ស.អ") រដ្ឋភាគីត្រូវតែ*«ធានាថា សិទ្ធិដែលមានចែងនៅក្នុងកតិកាសញ្ញាបច្ចុប្បន្ន នឹងត្រូវអនុវត្តដោយគ្មានការរើសអើង ទោះប្រភេទណាក៏ដោយ ចំពោះ [...] ឬឋានៈផ្សេងទៀតឡើយ»*[85] ហើយគណៈកម្មាធិការបានថ្លែងថា *«ឋានៈផ្សេងទៀត»* រួមបញ្ចូលទាំងនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ។[86]

34. ការស្រាវជ្រាវស្តីពីអ្នកប្តូរយេនឌ័រពីបុរសទៅស្ត្រីនៅកម្ពុជា ដែលធ្វើឡើងដោយម.ស.ម.ក នៅឆ្នាំ២០១៦ បានបង្ហាញថា អ្នកប្តូរយេនឌ័រពីបុរសទៅស្ត្រីប្រឈមនឹងការរើសអើងច្រើននៅក្នុងការងារ ដោយជួបការលំបាកនៅក្នុងការទទួល និងរក្សាបានការងារផ្លូវការ។[87] ជាងមួយភាគបី (៣៤.៣៥%) នៃអ្នកឆ្លើយសំណួរទាំងអស់ បានរាយការណ៍ថា ធ្លាប់ត្រូវបានគេបដិសេធការងារដោយសារតែខ្លួនជាអ្នកប្តូរយេនឌ័រ និង ២៦.៦២% នៃអ្នកឆ្លើយតបទាំងអស់ បាននិយាយថា ពួកគេធ្លាប់ត្រូវគេបញ្ឈប់ពីការងារដោយសារតែនិន្នាការភេទ អត្តសញ្ញាណយេនឌ័រនិងការបង្ហាញលក្ខណៈភេទ។[88] ការរកឃើញស្រដៀងគ្នានេះចេញពីការសិក្សាមួយ ដែលធ្វើឡើងដោយ NCHADS កាលពីឆ្នាំ២០១៦ បានបង្ហាញថា ៤២.១% នៃអ្នកប្តូរយេនឌ័រពីបុរសទៅស្ត្រីដែលបានស្ទង់មតិ ធ្លាប់ជួបបញ្ហាក្នុងការទទួលបានការងារ ចំណែកឯ ២៤.៣% ធ្លាប់ជួបបញ្ហាបាត់បង់ការងារ។[89]

35. ក្រៅពីការរើសអើងក្នុងការទទួលបានការងារ ប្រជាជនអ្នកស្រឡាញ់ភេទដូចគ្នា នៅកម្ពុជា ក៏ជួបប្រទះបញ្ហានៃការមិនរាប់បញ្ចូល និងការរើសអើងនៅក្នុងកន្លែងធ្វើការផងដែរ។ ម.ស.ម.ក កន្លងមក ធ្លាប់បានប្រមូលភស្តុតាងនៃការធ្វើបាបកម្រិតខ្ពស់ដែលត្រូវបានគេរាយការណ៍ថា កើតមាននៅក្នុងកន្លែងធ្វើការ ទៅលើអ្នកប្តូរយេនឌ័រពីបុរសទៅស្ត្រី ក្នុងនោះរាប់ទាំងការបៀតបៀន និងការធ្វើបាបផងដែរ ដោយមាន ២៦.៧២% នៃអ្នកប្តូរយេនឌ័រពីបុរសទៅស្ត្រីដែលបានស្ទង់មតិដោយ ម.ស.ម.ក បានរាយការណ៍ថា ធ្លាប់

ត្រូវប្រធាន ឬសហការីបៀតបៀន ឬធ្វើបាប ដោយសារតែ និន្នាការភេទ អត្តសញ្ញាណយេនឌ័រនិងការបង្ហាញលក្ខណៈភេទ របស់ពួកគាត់។[90]

## ស្ថានភាពសេដ្ឋកិច្ចរបស់ប្រជាជន អ្នកស្រលាញ់ភេទដូចគ្នា

36. ការស្ទង់មតិទូទាំងប្រទេសមួយដែលធ្វើឡើងដោយ រ៉ក់ កាលពីឆ្នាំ២០១៥ បានរកឃើញថា ការងារសំខាន់ជាងគេបំផុតទាំង ៦ សម្រាប់ប្រជាជនអ្នកស្រឡាញ់ភេទដូចគ្នា នៅកម្ពុជា រួមមាន (១) កសិករ (២) មុខរបរផ្ទាល់ខ្លួន/អាជីវករ (៣) សិស្ស-និស្សិត (៤) កម្មកររោងចក្រកាត់ដេរ (៥) វិស័យសេវាកម្ម និង (៦) អ្នកធ្វើការក្នុងវិស័យកសិកម្ម។[91] ការសិក្សាអំពីអ្នកប្តូរយេនឌ័រពីបុរសទៅស្ត្រីនៅតំបន់ទីក្រុងដែលធ្វើឡើងដោយ ម.ស.ម.ក កាលពីឆ្នាំ២០១៦បានបង្ហាញថា មួយផ្នែកធំដោយសារតែការរើសអើងនៅក្នុងការងារ អ្នកប្តូរយេនឌ័រប្រឈមមុខនឹងអត្រាគ្មានការងារធ្វើខ្ពស់ ហើយជារឿយៗ ត្រូវគេរុញឱ្យទៅស្វែងរកការងារនៅក្នុងមុខរបរចង្អៀត បន្ទាប់បន្សំ ឬសម្រាប់តែភេទស្រី (ដូចជា របរសេវាផ្លូវភេទ ធ្វើសក់ ផាត់មុខ ឬបោកគក់)។[92] ការសិក្សារបស់ ម.ស.ម.ក និងការស្រាវជ្រាវផ្សេងទៀត ក៏បានបង្ហាញផងដែរថា ជម្រើសវិស័យអាជីពដ៏ចង្អៀតទាំងនេះអាចនឹងបណ្តាលមកពីការរឹតត្បិតខ្លួនឯងពីក្នុងចិត្ត ដែលអ្នកប្តូរយេនឌ័រពីបុរសទៅស្ត្រីប្រកាន់យកនៅក្នុងបរិបទទូលំទូលាយនៃការរើសអើងនៅក្នុងសង្គម។[93]

37. ប្រជាជន អ្នកស្រឡាញ់ភេទដូចគ្នានៅកម្ពុជា ភាគច្រើនធ្វើការនៅក្នុងវិស័យរងការមើលស្រាលមួយចំនួនដែលរារាំងពួកគេមិនអាចគេចចេញពីវដ្តនៃភាពក្រីក្របាន។ ស្ថានភាពនេះត្រូវបានជុនជាបកាន់តែខ្លាំងឡើងថែមទៀតដោយសារ មិនរាប់បញ្ចូលពួកគេនៅក្នុងគ្រួសារ នៅតាមសាលារៀន និងនៅក្នុងសហគមន៍[94] ដែលបណ្តាលឱ្យប្រជាជនអ្នកស្រឡាញ់ភេទដូចគ្នាជាច្រើន ចាកចេញពីស្រុកកំណើតរបស់ខ្លួនដែលជាហេតុបង្កើតនូវវិបត្តិបន្ថែមដល់ពួកគេ។[95] ការធ្វើសមាហរណកម្មប្រជាជនអ្នកស្រឡាញ់ភេទដូចគ្នា ពេញលេញទៅក្នុងកម្លាំងពលកម្មកម្ពុជា ទីមួយ នឹងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន អ្នកស្រឡាញ់ភេទដូចគ្នា និងទីពីរ នឹងផ្តល់ផលប្រយោជន៍សេដ្ឋកិច្ចដល់ប្រទេសជាតិទាំងមូល។

## ផ្នត់គំនិតសង្គម និងការរើសអើងលើអ្នករកស៊ីផ្លូវភេទរបស់អ្នកស្រលាញ់ភេទដូចគ្នា

38. ការស្ទង់មតិឆ្នាំ២០១៦ របស់ ម.ស.ម.ក ស្តីពីអ្នកប្តូរយេនឌ័រពីបុរសទៅស្ត្រីបង្ហាញថា ការរើសអើងពីសំណាក់និយោជកអាចជាកត្តាចម្បងមួយ នៅក្នុងការបណ្តាលឱ្យអ្នកប្តូរយេនឌ័រពីបុរសទៅស្ត្រីងាកទៅរករបរសេវាផ្លូវភេទ។[96] ការស្ទង់មតិរបស់ ម.ស.ម.ក ក៏បានបង្ហាញផងដែរថា អ្នកប្តូរយេនឌ័រពីបុរសទៅស្ត្រីដែលប្រឡូកក្នុងរបរសេវាផ្លូវភេទ ទទួលរងនូវការរើសអើងធ្ងន់ធ្ងរនៅក្នុងទិដ្ឋភាពភាគច្រើនបំផុតនៃជីវិតរស់នៅប្រចាំថ្ងៃ។[97] សំខាន់ជាងនេះទៀត ក្នុងចំណោមអ្នកដែលបានរាយការណ៍ថា បានប្រឡូកក្នុងរបរសេវាផ្លូវ

ភេទនៅគ្រាមួយកាលពីពេលកន្លងមក មាន ៩៥.៧៤% ដែលធ្លាប់ទទួលរងការបៀតបៀនដោយពាក្យសម្តី ៩១.៣% ត្រូវគេបំពានរាងកាយ និង៨៥.១១% ត្រូវគេបំពានផ្លូវភេទ ក្នុងពេលប្រឡូកនូវមុខរបរសេវា ផ្លូវភេទ។[98] ការមាក់ងាយនិងការរើសអើងប្រឆាំងនឹងអ្នកប្តូរយេនឌ័រពីបុរសទៅស្ត្រីដែលប្រឡូកក្នុងមុខរបរសេវាផ្លូវភេទ ក៏បានរីករាលដាលទៅដល់ជីវិតឯកជនរបស់ពួកគេផងដែរ។[99]

## អនុសាសន៍

5. ធ្វើវិសោធនកម្មមាត្រា ១២ នៃច្បាប់ការងារឆ្នាំ១៩៩៧ ដើម្បីដាក់បញ្ចូលមាត្រាមួយដែលហាមឃាត់ការរើសអើងនៅកន្លែងការងារដែលផ្អែកលើមូលដ្ឋាន និន្នាការភេទ អត្តសញ្ញាណយេនឌ័រនិងការបង្ហាញលក្ខណៈភេទ ទាំងនៅក្នុងការងាររដ្ឋ និងនៅក្នុងការងារឯកជន ក្នុងនោះរាប់ទាំងការរើសអើងទាក់ទងនឹងការបណ្តុះបណ្តាលវិជ្ជាជីវៈ ការជ្រើសរើសបុគ្គលិក ការដំឡើងឋានៈ ការបញ្ឈប់ពីការងារ លក្ខខណ្ឌការងារ និងប្រាក់ឈ្នួល នៅមុនដំណាច់ឆ្នាំ២០២១ ស្របទៅតាម គោលដៅអភិវឌ្ឍប្រកបដោយចីរភាព ៨.៥។[100]

6. អនុវត្តគំនិតផ្តួចផ្តើមនានាដែលសំដៅធានាសិទ្ធិទទួលបានការងាររបស់ប្រជាជន អ្នកស្រឡាញ់ភេទដូចគ្នាក្នុងនោះរាប់បញ្ចូលទាំងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ។

7. ធានាការការពារប្រកបដោយប្រសិទ្ធភាពចំពោះប្រជាជន អ្នកស្រឡាញ់ភេទដូចគ្នាដែលប្រឡូកនៅក្នុងរបរសេវាផ្លូវភេទស្របទៅតាម គោលដៅអភិវឌ្ឍប្រកបដោយចីរភាពទី ៨។

## 5. ស្ថានភាពរបស់បុគ្គលអន្តរភេទ[101] នៅកម្ពុជា

39. ស្ថានភាពរបស់ប្រជាជនអន្តរភេទ គឺនៅមិនទាន់បានពិនិត្យនៅឡើយនៅក្នុងប្រទេសកម្ពុជា។ ទិន្នន័យរដ្ឋាភិបាល និងការស្រាវជ្រាវណាមួយដែលបានបោះពុម្ពផ្សាយរួច ស្តីពីប្រជាជនអន្តរភេទ និងបញ្ហាដែលពួកគេជួបប្រទះនៅក្នុងប្រទេសកម្ពុជា ទាក់ទងនឹងលទ្ធភាពទទួលសេវាសុខភាពរាងកាយ និងផ្លូវចិត្ត ទាក់ទងនឹងការចំអកសម្លុត និងការមិនរាប់បញ្ចូល ឬការអនុវត្តការវះកាត់ពាក់ព័ន្ធនឹងលក្ខណៈភេទរបស់ទារក និងកុមារអន្តរភេទ គឺពុំទាន់មាននៅឡើយទេ។

## អនុសាសន៍

6. គោរព ការពារ និងបំពេញនូវសិទ្ធិបុគ្គល អន្តរភេទនៅគ្រប់ច្បាប់ គោលនយោបាយ និងកម្មវិធីទាំងអស់ ជាពិសេស ទាក់ទងនឹងសុខភាព ការងារ និងការអប់រំ។

7. ធ្វើការស្រាវជ្រាវស្ដីពីស្ថានភាព និងសេចក្ដីត្រូវការរបស់ប្រជាជនអន្តរភេទ នៅក្នុងប្រទេសកម្ពុជា បន្ទាប់ពីពិគ្រោះយោបល់ជាមួយអ្នកជំនាញ និងសហគមន៍អន្តរភេទ នៅត្រឹមឆ្នាំ២០២២។

8. ធានាថា នីតិវិធីវេជ្ជសាស្ត្រទាំងអស់ស្របទៅតាមបទដ្ឋានសិទ្ធិមនុស្សជាធរមាន ក្នុងនោះរាប់បញ្ចូលទាំងការគាំទ្រផ្នែកផ្លូវចិត្តដល់សហគមន៍អន្តរភេទ។ ជាពិសេស ការពារ និងធានាថា គ្មានការវះកាត់ ឬប្រតិបត្តិការដែលគ្មានការយល់ព្រម និងមិនចាំបាច់តាមលក្ខណៈវេជ្ជសាស្ត្រណាមួយ ត្រូវបានធ្វើឡើងទៅលើទារក និងកុមារអន្តរភេទឡើយ។

## 6. សិទ្ធិសុខភាពរបស់ អ្នកស្រលាញ់ភេទដូចគ្នា

40. នៅក្នុងអំឡុងពេល យូ.ភី.អ លើកទីពីររបស់ខ្លួន ប្រទេសកម្ពុជាទទួលបាន ការគាំទ្រនូវអនុសាសន៍ចំនួន ១៦ ចំណុច ស្ដីពីសិទ្ធិសុខភាព ដែលពីរចំណុចសំដៅដោយផ្ទាល់ទៅលើ សិទ្ធិសុខភាពបន្តពូជ និងសិទ្ធិសុខភាពផ្លូវភេទ។[102] ទោះជាយ៉ាងណាក៏ដោយ ក៏ប្រជាជនអ្នកស្រឡាញ់ភេទដូចគ្នា នៅកម្ពុជា នៅតែប្រឈមមុខនឹងឧបសគ្គជាច្រើនដែលរារាំង ដល់ការទទួលបានភាពពេញលេញនូវសិទ្ធិសុខភាពរបស់ពួកគេ។ ចំណេះដឹង និងការយល់ដឹងអំពី និន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញលក្ខណៈភេទ នៅមានកម្រិតទាបនៅឡើយនៅក្នុងចំណោមអ្នកប្រកបវិជ្ជាជីវៈវេជ្ជសាស្ត្រនៅប្រទេសកម្ពុជា ហើយការបញ្ជ្រាបការយល់ដឹង និងការកសាងសមត្ថភាពលើបញ្ហានេះ កន្លងមក នៅមានកម្រិតតិចតួចនៅឡើយ។ ដូច្នេះហើយទើបនៅមានការរឹតត្បិតទាក់ទងនឹងការផ្ដល់សេវាសុខភាព ដែលបំពេញតាមតម្រូវការរបស់ប្រជាជនអ្នកស្រឡាញ់ភេទដូចគ្នា ។ ផ្នែកនេះពិនិត្យទៅលើលទ្ធភាពទទួលបានការព្យាបាលសម្រាប់ប្រជាជន អ្នកស្រឡាញ់ភេទដូចគ្នា ដែលផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ លទ្ធភាពទទួលបានការថែទាំសុខភាពគ្រប់ជ្រុងជ្រោយសម្រាប់ប្រជាជនអ្នកប្ដូរយេនឌ័រនិងលទ្ធភាពទទួលបានការរំលូតកូនដោយស្របច្បាប់ និងដោយសុវត្ថិភាពសម្រាប់ស្ត្រីស្រឡាញ់ស្ត្រី និងអ្នកប្ដូរយេនឌ័រពីស្ត្រីទៅបុរស ។

### *ការទទួលបានការព្យាបាលសម្រាប់ អ្នកស្រលាញ់ភេទដូចគ្នា ដែលផ្ទុកមេរោគអេដស៍/ជំងឺអេដស៍*

41. ក្នុងអំឡុងវគ្គ យូ.ភី.អ លើកទីពីរ រាជរដ្ឋាភិបាលកម្ពុជា បានទទួលយកអនុសាសន៍ *«ផ្ដល់ការព្យាបាលដោយឥតគិតថ្លៃដល់ស្ត្រី និងបុរសដែលផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ ដើម្បីបង្ការការឆ្លងពីម្ដាយទៅកូន»*។[103] រយៈពេលពីរទសវត្សរ៍កន្លងមកនេះ គេសង្កេតឃើញមានការវិវឌ្ឍន៍ជាវិជ្ជមាន នៅក្នុងការឆ្លើយតបទៅនឹងមេរោគអេដស៍របស់ប្រទេសកម្ពុជា។[104]

42. ទោះបីមានវឌ្ឍនភាពបែបនេះក្តី ប្រេវ៉ាឡង់មេរោគអេដស៍នៅតែមានកម្រិតខ្ពស់នៅឡើយ ក្នុងចំណោមប្រជាជនដែលមានហានិភ័យខ្ពស់ ក្នុងនោះរាប់បញ្ចូលទាំងបុគ្គលិកធ្វើការក្នុងវិស័យកម្សាន្ត បុរសដែលរួមភេទជាមួយបុរស អ្នកប្តូរយេនឌ័រពីបុរសទៅស្ត្រី និងអ្នកប្រើប្រាស់គ្រឿងញៀន។[105] ជាងនេះទៅទៀត ប្រជាជនអ្នកស្រឡាញ់ភេទដូចគ្នា អាយុក្រោម១៨ ឆ្នាំ ជាធម្មតា ត្រូវគេបដិសេធ ការទទួលសេវាធ្វើតេស្តឈាមរកមេរោគអេដស៍ នៅក្រោមច្បាប់ និងគោលនយោបាយដែលមានស្រាប់ ដែលជារឿយៗបន្ទប់បង្អាក់ដល់លទ្ធភាពរបស់ពួកគេក្នុងការទទួលសេវាធ្វើតេស្ត។[106] ឧបសគ្គផ្នែកច្បាប់ និងរចនាសម្ព័ន្ធសំខាន់ៗ ព្រមទាំងផ្នត់គំនិតសង្គម និងការរើសអើងចំពោះសហគមន៍ដែលប្រឈមហានិភ័យ នៅតែមាននៅឡើយ ដែលបន្តរារាំងការទទួលបានសេវាសុខភាព និងសេវាមិនមែនសុខភាពទាក់ទងនឹងមេរោគអេដស៍របស់ក្រុមទាំងនេះ។ បន្ថែមលើនេះ ការប្រើប្រាស់ស្រោមអនាម័យជាប់លាប់ក្នុងចំណោមក្រុមទាំងនេះ[107] ការធ្វើតេស្តរកមេរោគអេដស៍ និងការពិនិត្យជំងឺកាមរោគ នៅមានកម្រិតទាបនៅឡើយ។[108]

43. ប្រទេសកម្ពុជាបានប្តេជ្ញាចិត្តបញ្ចប់ជំងឺអេដស៍ នៅត្រឹមឆ្នាំ២០២៥ គឺ ៥ឆ្នាំនៅមុនទិសដៅសកលលោក ដែលបានកំណត់នៅក្នុង គោលដៅអភិវឌ្ឍប្រកបដោយចីរភាព ។[109] ដើម្បីសម្រេចគោលដៅនេះ កិច្ចប្រឹងប្រែងបន្ថែមទៀតចាំបាច់ត្រូវធ្វើឡើង ជាពិសេស ដើម្បីធានាថា ប្រជាជនដែលប្រឈមហានិភ័យខ្ពស់ត្រូវបានផ្សព្វផ្សាយទៅដល់គោលដៅ ប្រកបដោយប្រសិទ្ធភាព ជាមួយនឹងកញ្ចប់សេវាជាខ្សែសង្វាក់ពី ការបង្ការ ហូតដល់ការថែទាំ និងសេវាព្យាបាល និងធានាថា ប្រជាជនផ្ទុកមេរោគអេដស៍ដែលមិនបានធ្វើតេស្ត ដឹងពីស្ថានភាពរបស់ខ្លួន និងចុះឈ្មោះដើម្បីទទួលបានសេវាបង្ការ និងព្យាបាលមេរោគអេដស៍។

## ***ការទទួលបានសេវាសុខភាព និងព័ត៌មានពីសេវាសុខភាពគ្រប់ជ្រុងជ្រោយសម្រាប់អ្នកប្តូរយេនឌ័រ***

44. នៅក្នុងអំឡុងវដ្ត យូ.ភី.អ លើកទីពីរ រាជរដ្ឋាភិបាលកម្ពុជា បានទទួល និងគាំទ្រអនុសាសន៍ក្នុងការ «បង្កើនកិច្ចប្រឹងប្រែងជាបន្ត ដែលសំដៅលើកកម្ពស់សិទ្ធិសុខភាពប្រកបដោយសមធម៌ សម្រាប់ប្រជាជនកម្ពុជាគ្រប់រូប»។[110] ទោះបីជាមានកិច្ចប្រឹងប្រែងពីសំណាក់ រាជរដ្ឋាភិបាលកម្ពុជា ក្នុងការបង្កើនលទ្ធភាពទទួលបានការថែទាំសុខភាពអ្នកប្តូរយេនឌ័រ នៅតែប្រឈមមុខនឹងឧបសគ្គក្នុងការទទួលបានសេវា និងព័ត៌មានអំពីសេវាសុខភាពគ្រប់ជ្រុងជ្រោយ ក្នុងនោះរាប់ទាំងការព្យាបាលដោយអ័រម៉ូន ជំនួយសុខភាពផ្លូវចិត្ត និងជំនួយផ្នែកច្បាប់។

45. មិនមានសេវាថែទាំសុខភាពទាក់ទងនឹងអ្នកប្តូរយេនឌ័រឡើយ ហើយក៏គ្មានច្បាប់ បទប្បញ្ញត្តិ ឬឯកសាររដ្ឋបាល ដែលចែងថា តើសេវាបែបនេះស្របច្បាប់ ឬខុសច្បាប់ នោះឡើយ។ ជាផលវិបាក សេវាបែបនេះអាចរកបាន គឺមិនស្ថិតក្រោមការត្រួតពិនិត្យត្រឹមត្រូវនោះទេ។[111] ដោយមូលហេតុនេះហើយ ទើបប្រជាជន

អ្នកប្តូរយេនឌ័រនៅកម្ពុជា តែងតែធ្វើដំណើរទៅកាន់ប្រទេសផ្សេងដើម្បីស្វែងរកការវះកាត់[112] ហើយប្រជាជនអ្នកស្រឡាញ់ភេទដូចគ្នាជាច្រើន ពឹងផ្អែកលើមិត្តភក្តិរបស់ខ្លួនដើម្បីសាកសួរព័ត៌មានអំពីប្រតិបត្តិការវះកាត់ប្តូរយេនឌ័រ ហើយអ្នកខ្លះថែមទាំងអនុវត្តការថែទាំវេជ្ជសាស្ត្រដោយខ្លួនឯងទៀតផង ដែលអាចនឹងបណ្តាលឱ្យមានផលវិបាកធ្ងន់ធ្ងរ ហើយផលប៉ះពាល់ពីទង្វើបែបនេះត្រូវបានរាយការណ៍ថា មានកើតមានផងដែរ។[113]

46. ជាងនេះទៅទៀត ប្រជាជន អ្នកស្រឡាញ់ភេទដូចគ្នាប្រឈមមុខនឹងបញ្ហាទាក់ទងនឹងសុខភាពផ្លូវចិត្តជាច្រើន មួយផ្នែកគឺដោយសារតែការរើសអើងពាក់ព័ន្ធនឹង និន្នាការភេទ អត្តសញ្ញាណយេនឌ័រនិងការបង្ហាញលក្ខណៈភេទរបស់ពួកគេ។ ជាក់ស្តែង ២២% នៃប្រជាជនអ្នកស្រឡាញ់ភេទដូចគ្នារាយការណ៍ថា មានអារម្មណ៍ខ្មាសអៀនចំពោះខ្លួនពួកគេ នេះបើផ្អែកតាមការសិក្សាមួយរបស់ រ៉ក់ ដែលបានធ្វើឡើងកាលពីឆ្នាំ២០១៥។[114] បច្ចុប្បន្ន សេវាសុខភាពផ្លូវចិត្តដែលជាក់លាក់សម្រាប់ អ្នកស្រឡាញ់ភេទដូចគ្នានៅមានកម្រិតតិចតួចណាស់នៅក្នុងប្រទេសកម្ពុជា។

## ***ការទទួលបានព័ត៌មានអំពីសុខភាពបន្តពូជ និងការរំលូតកូនដោយស្របច្បាប់ និងដោយសុវត្ថិភាព សម្រាប់ស្ត្រីស្រឡាញ់ស្ត្រី ស្ត្រីស្រឡាញ់ទាំងពីរភេទ អន្តរភេទ និងអ្នកប្តូរយេនឌ័រពីស្ត្រីទៅបុរស***

